**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អគ្គនាយកដ្ឋានការងារ**

**នាយកដ្ឋានអធិការកិច្ចការងារ**

លេខៈ...០០៤/២១........ក.ប/អ.ក/អ.ធ.ក/ប.ព.ក

**ជម្រាបមក**

**លោក ម្ចាស់ ឬនាយកក្រុមហ៊ុន អ៊ី អិម ប៊ី ដែលកូវី (ខេមបូឌា)**

**កម្មវត្ថុ** ៖ ការអនុញ្ញាតបញ្ចប់ការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតមុនកាលកំណត់

**យោង** ៖ -លិខិតស្នើសុំរបស់ក្រុមហ៊ុន អ៊ី អិម ប៊ី ដែលកូវី (ខេមបូឌា)

-លិខិតអនុញ្ញាតឱ្យព្យួរកិច្ចសន្យាការងារលេខ ០៣៩/២១ ក.ប/អ.ក/អ.ធ.ក/ព.ក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **លោក ម្ចាស់ ឬនាយក** ថា បន្ទាប់ពីបានពិនិត្យលើការស្នើសុំបញ្ចប់ការព្យួរកិច្ចសន្យាការងារកម្មករនិយោជិត ក្រសួងសម្រេចអនុញ្ញាតឱ្យបញ្ចប់ការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ២១នាក់ (ស្រី ២០នាក់) ក្នុងចំណោមកម្មករនិយោជិតដែលបានសុំព្យួរសរុបចំនួន ៤៥នាក់ (ស្រី ៣២នាក់) ចាប់ពីថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១ នេះទៅ។

អាស្រ័យដូចនេះ សូម **លោក ម្ចាស់ ឬនាយក** បិទផ្សាយនូវលិខិតនេះ ជូនកម្មករនិយោជិតឱ្យបានជ្រាបគ្រប់ៗគ្នា។

សូម **លោក ម្ចាស់ ឬនាយក** ទទួលនូវសេចក្តីរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

ថ្ងៃ ៧ ៥ ៣ ខែ ផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១

**ត.ប. រដ្ឋមន្ត្រី**

**ប្រធាននាយកដ្ឋានអធិការកិច្ចការងារ**

**អ៊ុក ចាន់ធូ**

**ចម្លងជូន:**

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងទេសចរណ៍ (សម្រាប់វិស័យទេសចរណ៍)
- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ក្រសួងរ៉ែ និងថាមពល
- ធនាគារជាតិនៃកម្ពុជា
- អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បេឡាជាតិសន្តិសុខសង្គម
- ទីភ្នាក់ងារជាតិមុខរបរ និងការងារ
- រដ្ឋបាលរាជធានីភ្នំពេញ